**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**អគ្គនាយកដ្ឋានស្រាវជ្រាវ**
**នាយកដ្ឋានស្រាវជ្រាវថវិកា**

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ការនាំចេញរបស់ប្រទេសកម្ពុជាទៅកាន់ប្រទេស ជប៉ុនមានទឹកប្រាក់១,៤ប៊ីលានដុល្លារគិតត្រឹមរយៈពេល១០ខែនៃឆ្នាំ២០២១
- ថវិការបស់គម្រោងសហហិរញ្ញប្បទាន សម្រាប់សហគ្រាសធុនតូច និងមធ្យមបានកើនឡើងដល់ ១៤០លានដុល្លារ
- តើមេរោគបំប្លែងថ្មីអូមីក្រុង នឹងបង្ករាំងស្ទះដល់វិស័យធនាគារ និងហិរញ្ញវត្ថុឆ្នាំ២០២២ ដែរឬយ៉ាងណា?
- ក្នុងខែវិច្ឆិកាឆ្នាំនេះ គម្រោងវិនិយោគថ្មី១៥ ទុនវិនិយោគជាង៥៤៨លានដុល្លារ ត្រូវបានអនុម័ត
- ១១ខែឆ្នាំ កម្ពុជា នាំចេញផលិតផលដំឡូងមីជាង២លានតោនទៅកាន់អាស៊ី អាមេរិក និងអឺរ៉ុប
- គម្រោងកំពង់ផែទឹកជ្រៅតម្លៃ ២០០លានដុល្លារនៅខេត្តព្រះសីហនុនឹងជួយដោះស្រាយបញ្ហាដឹកជញ្ជូន
- សេដ្ឋកិច្ចវៀតណាម ត្រូវបានប៉ាន់ប្រមាណថានឹងខាតបង់ ៣៧ប៊ីលានដុល្លារអាមេរិក ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ គិតត្រឹមចុងឆ្នាំ២០២១
- ពាណិជ្ជកម្មវៀតណាម សម្រាប់ពាក់កណ្តាលខែ ដំបូង នៃខែកញ្ញា ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)
- IMF ទំនងជានឹងកាត់បន្ថយការព្យាករណ៍កំណើនតំបន់អឺរ៉ូចំពេលអតិផរណា ដោយសារភ័យខ្លាច អូមីក្រុង
- តើសេដ្ឋកិច្ចចិនឆ្នាំ២០២២ នឹងប្រែប្រួល ឬជួបកត្តាប្រឈមអ្វីខ្លះ?


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី៣ ខែធ្នូ ឆ្នាំ២០២១ លេខ ៖ ៩៧

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការនាំចេញរបស់ប្រទេសកម្ពុជាទៅកាន់ប្រទេសជប៉ុនមានទឹកប្រាក់១,៤ប៊ីលានដុល្លារគិតត្រឹមរយៈពេល១០ខែនៃឆ្នាំ២០២១




*ប្រភព៖ khmertimes, 2021 រូបភាព៖ ជិវ សុគន្ធា*

យោងតាមការបង្ហាញតួលេខរបស់អង្គការពាណិជ្ជកម្មក្រៅស្រុករបស់ជប៉ុន(JETRO) បានបញ្ជាក់ថា៖ ការនាំចេញទំនិញរបស់កម្ពុជាទៅកាន់ប្រទេសជប៉ុនមានចំនួនសរុប ១,៤៨ ប៊ីលានដុល្លារក្នុងរយៈពេល ១០ ខែឆ្នាំនេះ កើនឡើង ៩,៣% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ចាប់ពីខែមករា ដល់ខែតុលា ប្រទេសកម្ពុជា បាននាំចូលទំនិញពីប្រទេសអាស៊ីបូព៌ា មានតម្លៃ ៤៤៧លានដុល្លារ កើនឡើង ២២,២% ធៀបនឹងឆ្នាំមុន។ លទ្ធផលនេះបានធ្វើឲ្យអតិរេកពាណិជ្ជកម្មរបស់កម្ពុជាជាមួយជប៉ុនមានចំនួន ១, ០១ប៊ីលានដុល្លារ។

ការនាំចេញទំនិញសំខាន់ៗទៅកាន់ប្រទេសជប៉ុនគឺ សម្លៀកបំពាក់ កាបូប ស្បែកជើង គ្រឿងសង្ហារឹម គ្រឿងសំអាង ក្រដាស និងសម្ភារៈការិយាល័យ និងទំនិញប្រភេទស្បែក។ កម្ពុជាបាននាំចូលគ្រឿងចក្ររថយន្ត គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម ក្រណាត់ និងប្លាស្ទិកពីប្រទេសជប៉ុន។

ស្របពេលជាមួយគ្នានេះដែរ,ក្រសួងពាណិជ្ជកម្មបានបញ្ជាក់ថា៖ប្រទេសកម្ពុជាសម្លឹងមើលប្រទេសជប៉ុនជាដៃគូពាណិជ្ជកម្មអាទិភាពសម្រាប់ការពិភាក្សាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីដែលនឹងត្រូវបង្កើតឡើង កិច្ចពិភាក្សានេះគ្រោងនឹងធ្វើឡើងក្នុងពេលឆាប់ៗនេះ ខណៈដែលប្រទេសកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីចំនួនពីររួចមកហើយ ដែលមួយគឺមួយជាមួយប្រទេសចិន និងកូរ៉េខាងត្បូង។

លោក Mikami Masahiro ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា បានមានប្រសាសន៍ថា ច្បាប់វិនិយោគថ្មីនៃព្រះរាជាណាចក្រកម្ពុជា នឹងជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាព និងទាន់ពេលវេលាសម្រាប់ការស្តារសេដ្ឋកិច្ចសង្គមឡើងវិញបន្ទាប់ពីវិបត្តិនៃជំងឺរាតត្បាតកូវីដ-១៩ ហើយធ្វើឲ្យកម្ពុជាក្លាយជាគោលដៅទាក់ទាញ និងប្រកួតប្រជែងខ្ពស់ក្នុងតំបន់សម្រាប់ការវិនិយោគប្រកប ដោយគុណភាព និងនិរន្តរភាព។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បានអនុម័តគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់ប្រទេសជប៉ុន (QIP) ចំនួន ១៤៦ គិតត្រឹមខែតុលា ជាមួយនឹងទុនវិនិយោគសរុបចំនួន ២,៨ប៊ីលានដុល្លារ។ ក្នុងចំណោមគម្រោងវិនិយោគដែលបានអនុម័តនោះ មានគម្រោងវិនិយោគចំនួន៦៦ដែលមានទុនវិនិយោគសរុប ៣៤០ លានដុល្លារស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ច

ពិសេស។ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)ក៏គ្រោងនឹងបង្កើតទំនាក់ទំនងបរទេសនៅក្រៅប្រទេសផងដែរ ដើម្បីជំរុញការវិនិយោគពីបរទេស ដោយលើកឡើងថា ប្រទេសជប៉ុនគឺជាប្រទេសមួយក្នុងចំណោមប្រទេសដែល គ្រោងនឹងបង្កើតការិយាល័យ និងជាទីផ្សារធំបំផុតមួយរបស់កម្ពុជា បន្ទាប់ពីអាមេរិក និងសហភាពអឺរ៉ុប។ ក្នុងឆ្នាំ ២០២០ ពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរមានតម្លៃ ២,០៩ប៊ីលានដុល្លារ ធ្លាក់ចុះ ៨% បើធៀបនឹងឆ្នាំ ២០១៩។ ជប៉ុនជាទីផ្សារធំបំផុតមួយរបស់កម្ពុជា បន្ទាប់ពីអាមេរិក និងសហភាពអឺរ៉ុប៕ *ដោយ សេន ចន្ធី*

*ប្រភព៖khmertimes.ចេញផ្សាយថ្ងៃទី០៦ខែធ្នូ ឆ្នាំ២០២១*

## ថវិការបស់គម្រោងសហហិរញ្ញប្បទាន សម្រាប់សហគ្រាសធុនតូច និងមធ្យមបានកើនឡើងដល់ ១៤០លានដុល្លារ




*ប្រភព៖ khmertimes, 2021 រូបភាព៖ ជរ សុគន្ធា*

ធនាគារសហគ្រាសធុនតូច និងមធ្យម( SME Bank) បានបន្ថែមទឹកប្រាក់ចំនួន៤០លានដុល្លារទៅក្នុងគម្រោងសហហិរញ្ញប្បទាន II (SCFS II) ដែលនាំមកនូវថវិកាសរុបរហូតដល់ ១៤០ លានដុល្លារសម្រាប់គាំទ្រដល់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា។

យោងតាមសេចក្តីថ្លែងការណ៍មួយរបស់ធនាគារបានបញ្ជាក់ថា ថវិកាបន្ថែមរបស់ SCFS II គឺដើម្បីឆ្លើយតបទៅនឹងតម្រូវការតេណទានពីសហគ្រាសធុនតូច និង មធ្យម។ដោយសារតម្រូវការតេណទានច្រើនពេក សហគ្រាសធុនតូច និងមធ្យមត្រូវការតេណទានច្រើន ដើម្បីស្របតាមផែនការស្តារសេដ្ឋកិច្ចដែលផ្តួចផ្តើមដោយរាជរដ្ឋាភិបាលដូចនេះ ធនាគារ SME នៃកម្ពុជារួមជាមួយនឹងស្ថាប័នហិរញ្ញវត្ថុដែលបានចូលរួម (PFIs) បានសម្រេចផ្តល់ថវិកាបន្ថែម៤០ លានដុល្លារសម្រាប់ គម្រោងសហហិរញ្ញប្បទាន (SCFS II) ដែលមានចំនួនសរុប១៤០ លានដុល្លារ។

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈធនាគារសហគ្រាសធុនតូច និងមធ្យម បានចាប់ផ្តើមដំណើរការគម្រោង SCFS II ចាប់តាំងពីថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០២១ ដោយសហការជាមួយស្ថាប័នហិរញ្ញវត្ថុចូលរួមចំនួន ២៨ ដើម្បីគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា។

គិតត្រឹមថ្ងៃទី ៣០ ខែវិច្ឆិកា ការផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុដល់សហគ្រាសធុនតូច និងមធ្យមមានចំនួន ៧៩០ ដែលស្មើនឹង ៩៩,៨ លានដុល្លារជាចំនួនប្រាក់កម្ចីដែលស្ទើរតែឈានដល់១០០%នៃមូលនិធិបម្រុងដំបូងរបស់មូលនិធិចំនួន១០០ លានដុល្លារ។

តាមរយៈមូលនិធិនេះ ប្រធានសមាគមសហព័ន្ធសហគ្រាសធុនតូច និងមធ្យមកម្ពុជា បានសាទរចំពោះចំណាត់ការនេះដែលបង្ហាញថារដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការជួយសហគ្រាសធុនតូច និងមធ្យមទទួលបានថវិកាដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍អាជីវកម្មរបស់ពួកគេ។ ទន្ទឹមនឹងនេះ អាជីវកម្មអាចដើបឡើងវិញ ហើយក៏ជួយកម្មករឲ្យមានការងារធ្វើផងដែរ។

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានបង្ហាញទិន្នន័យបច្ចុប្បន្នមានសហគ្រាសធុនតូច និងមធ្យមដែលបានចុះបញ្ជីចំនួន ៤៣ ២៧៦

សហគ្រាស និងបាន បង្កើតការងារបានចំនួន ៤៣៥ ៩០៥ កន្លែង៕ *ដោយ សេន ចន្ទី*

*ប្រភព៖khmertimes. ចេញផ្សាយថ្ងៃទី០៧ខែធ្នូ ឆ្នាំ២០២១*

## តើមេរោគបំប្លែងថ្មីអូមីក្រុង នឹងបង្ករាំងស្ទះដល់វិស័យធនាគារ និងហិរញ្ញវត្ថុឆ្នាំ២០២២ ដែរឬយ៉ាងណា?



*ទិដ្ឋភាពទីក្រុងភ្នំពេញ (រូបភាព៖ ខេមបូណូមីស)*

អ្នកជំនាញវិស័យធនាគារ និង ហិរញ្ញវត្ថុនៅកម្ពុជា នៅតែមានទំនុកចិត្ត ភាពជឿជាក់ខ្ពស់ ចំពោះការរីកលូតលាស់ នៃវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុនៅឆ្នាំ២០២២ ទោះបីជា បច្ចុប្បន្នពិភពលោករួមទាំងកម្ពុជា កំពុងព្រួយបារម្ភពីមេរោគកូវីដ-១៩បំប្លែងខ្លួនថ្មីអូមីក្រុង ក៏ដោយ។ ការរំពឹងបែបនេះដោយផ្អែកលើយន្តការច្បាស់លាស់របស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ជំងឺកូវីដ-១៩ និងការអភិវឌ្ឍឥតឈប់ឈរលើប្រព័ន្ធឌីជីថលរបស់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុក្នុងការផ្តល់សេវាហិរញ្ញវត្ថុជូនអតិថិជន។ ជាក់ស្តែង នៅក្នុងឆ្នាំ២០២១ វិស័យធនាគារ និង ហិរញ្ញវត្ថុនៅកម្ពុជានៅតែរក្សាបាននូវកំណើនរឹងមាំ ទោះបីមានការរំខានអុកឡុកពីជំងឺរាតត្បាតកូវីដ-១៩។

ប្រធានសមាគមធនាគារនៅកម្ពុជា និងជាប្រធាននាយកប្រតិបត្តិនៃធនាគារអេស៊ីលីដា នៅតែមានភាពជឿជាក់ខ្ពស់បន្ទាប់ពីមើលឃើញពីការរីកលូតលាស់នៃវិស័យហិរញ្ញវត្ថុនៅឆ្នាំ២០២១ នៅតែមានកំណើនល្អ ទាំងកម្ពុជាស្ថិតក្នុងវិបត្តិកូវីដ-១៩ គួបផ្សំការខិតខំប្រឹងប្រែងអភិវឌ្ឍឥតឈប់ឈរលើប្រព័ន្ធបច្ចេកវិទ្យាឌីជីថលរបស់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន។ ការដាក់ចេញវិធានការច្បាស់លាស់ក្នុងការទប់ស្កាត់ការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ក៏ជាកត្តារួមចំណែកមួយផងដែរ។

សម្រាប់ធនាគារអេស៊ីលីដាផ្ទាល់ បានអះអាងថា គ្មានគម្រោងកាត់បន្ថយក្នុងការផ្តល់ឥណទានជូនអតិថិជននោះទេ គឺបានត្រៀមដើមទុនរាប់រយលានដុល្លាររួចហើយ ដើម្បីឥណទានជូនអតិថិជន។

របាយការណ៍ប្រចាំឆមាសទី១ របស់ធនាគារជាតិ នៃកម្ពុជាបានបង្ហាញថា ប្រព័ន្ធធនាគារ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុវិញ គឺនៅបន្តមានភាពធន់ និងបានផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព។ ទ្រព្យសកម្មប្រព័ន្ធធនាគារបានកើនឡើង ១៨% ឥណទានអតិថិជនមានកំណើនជាង ២៣% និងប្រាក់បញ្ញើអតិថិជនវិញកើនជិត២១%៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១។*

## ក្នុងខែវិច្ឆិកាឆ្នាំនេះ គម្រោងវិនិយោគថ្មី១៥ ទុនវិនិយោគជាង៥៤៨លានដុល្លារ ត្រូវបានអនុម័ត




នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១នេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)បានអនុម័តគម្រោង វិនិយោគថ្មីៗចំនួន ១៥ ដែលមានទុនវិនិយោគសរុបជាង ៥៤៨,៣លាន

ដុល្លារអាមេរិក។ តាមសំណើសុំវិនិយោគរបស់ក្រុមហ៊ុន គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានសម្រេចចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ដូចខាងក្រោម ៖

១៖ RMA AUTOMOTIVE (CAMBODIA) CO., LTD: រោងចក្រផ្គុំ និងដំឡើងរថយន្ត ដែលមានទីតាំងវិនិយោគស្ថិតនៅផ្លូវជាតិលេខ៥ ភូមិសារវ៉ន ឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់។

២៖ EM AUTOMOBILE CO., LTD: រោងចក្រផ្គុំ ដំឡើងគ្រឿងចក្រ រថយន្តសណ្តោង និងរថយន្តដឹកទំនិញធុនធ្ងន់គ្រប់ប្រភេទ ដែលមានទីតាំងវិនិយោគស្ថិតនៅផ្លូវជាតិលេខ៤៨ ភូមិឈូក ឃុំដីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង។

៣៖ SCHNEITEC WESTERN CO., LTD: គម្រោងសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនី ៥០០គីឡូវ៉ុល ពីបាត់ដំបងទៅព្រំដែនកម្ពុជា-ថៃ។

៤៖ SCHNEITEC NORTHERN CO., LTD: គម្រោងសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនី ៥០០គីឡូវ៉ុល ពីរាជធានីភ្នំពេញទៅព្រំដែនកម្ពុជា-ឡាវ។

៥៖ SMART TEX GARMENT (CAMBODIA) CO., LTD: រោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិព្រៃចាស់ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

៦៖ REMONDA (CAMBODIA) APPAREL CO., LTD: រោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិអង្គស្នួលទី៣ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល។

៧៖ CATHAYA INDUSTRY (CAMBODIA) CO., LTD: រោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងវិនិយោគស្ថិតនៅផ្លូវជាតិលេខ៤៤ ភូមិសន្តិភាព ឃុំតាំងក្រូច ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

៨៖ HENGWIN (CAMBODIA) GARMENT CO., LTD: រោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិក្រាំងគាំ ឃុំត្បែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

៩៖ JW ZHONGRUN (CAMBODIA) GARMENT CO., LTD: រោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិកន្ទោកជើង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ។

១០៖ WTX LEADING FASHION CO., LTD: រោងចក្រកាត់ដេរ និងចាក់សម្លៀកបំពាក់ ដែលមានទីតាំងវិនិយោគស្ថិតនៅក្បាលដីលេខ០៩៩៤ ផ្លូវជាតិលេខ២១ ភូមិព្រែកខ្សេវ សង្កាត់កោះខ្លស់ ក្រុងតាខ្មៅ ខេត្តកណ្តាល។

១១៖ CLOTHO (CAMBODIA) CO., LTD: រោងចក្រផលិតកាបូប ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិក្បាលដំរី២ សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

១២៖ HUN TY REAL ESTATE CO., LTD: រោងចក្រកែច្នៃផ្លែឈើ និងផលិតសម្ភារវេចខ្ចប់ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិវាល ឃុំកំពង់សីលា ស្រុកកំពង់សីលា ខេត្តព្រះសីហនុ។

១៣៖ KULARA WATER CO., LTD: រោងចក្រផលិតទឹកបរិសុទ្ធ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិស្រយង់ត្បូង ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ។

១៤៖ SUN PLEASURE (CAMBODIA) CO., LTD: រោងចក្រផលិតពោងខ្យល់គ្រប់ប្រភេទ ទូកកាយ៉ាក់ និងសម្ភារៈបរិក្ខាពាក់ព័ន្ធនឹងពោងគ្រប់ប្រភេទ ដែលមានទី

តាំងវិនិយោគស្ថិតនៅភូមិព្រៃខ្លា ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល។

១៥៖ ADVANT TRAVEL GOODS (CAMBODIA) CO., LTD រោងចក្រផលិតវ៉ាលិសគ្រប់ប្រភេទ និងកៅអីចល័តសម្រាប់ដំណើរកម្សាន្ត ដែលមាន ទីតាំងវិនិយោគ ស្ថិតនៅភូមិស្លា ឃុំវល្លិសរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

នេះបញ្ជាក់ឱ្យឃើញថា ទោះបីកម្ពុជាជួបប្រទះនូវវិបត្តិនៃជំងឺកូវីដ១៩ ក្ដី ក៏កម្ពុជានៅតែទាក់ទាញ នូវការវិនិយោគថ្មីៗបន្ថែមទៀត និងបង្កើតការងារបានរាប់ពាន់កន្លែង៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១។*

## ក្រុមហ៊ុនក្នុងស្រុក២ចាប់ដៃគ្នា នាំអាហារក្រៀមកែច្នៃពីផ្លែឈើស្រស់ ទៅកាន់ទីផ្សារក្នុង និងក្រៅប្រទេស




*ដោយ cnc*

ក្រុមហ៊ុនឯកជនក្នុងស្រុកចំនួន២គឺ ក្រុមហ៊ុន ណាវីតា ហែលស៊ីហ្វូដ បេវើរីច និងក្រុមហ៊ុនស៊ីអាក្រូខេមប្រូដាក់ បានចុះអនុស្សារណៈយោគយល់លើកិច្ចព្រមព្រៀង រួមគ្នាក្នុងការជំរុញ និងចែកចាយផលិតផលអាហារក្រៀមផលិតចេញពីផ្លែឈើស្រស់ មាន ម្នាស់ ស្វាយ ស្រការនាគ និងប៉េងប៉ោះជាដើម ធ្វើឱ្យទៅជាអាហារក្រៀម ឬដំណាប់ រឺងផ្លែតាង៉ែន(មៀនប៉ៃលិន)កែច្នៃដាក់កំប៉ុង ឬកែវ សម្រាប់នាំយកទៅលក់នៅលើទីផ្សារក្នុង និងក្រៅប្រទេស។

អ្នកសម្របសម្រួលផ្នែកទីផ្សាររបស់អង្គការកម្ពុជា ហាវ៉េសធូ បានចាត់ទុកថា ការចុះកិច្ចព្រមព្រៀងគ្នានេះ ជាកម្មវិធីមួយដ៏មានសារសំខាន់ក្នុងការរកទីផ្សារដល់កសិករ និងក្រុមអ្នកផលិតលើខ្សែសង្វាក់ផលិតកម្មកសិកម្ម។

អគ្គនាយកក្រុមហ៊ុនណាវីតាហែលស៊ីហ្វូដ បេវើរីច និងអគ្គនាយិកាក្រុមហ៊ុន ស៊ីអាក្រូខេមប្រូដាក់ខូ បានលើកឡើងដែរថា ការចុះអនុស្សារណៈនេះ គឺដើម្បីធ្វើកិច្ចសហការល្អក្នុងភាពជាដៃគូរជាមួយគ្នា និងជួយជំរុញផលិតផលណាវីតាចូលទៅកាន់ទីផ្សារ ក្រោមការជួយជ្រោមជ្រែង ឧបត្ថម្ភពីអង្គការកម្ពុជា ហាវ៉េសធូ ដែលជាគម្រោងក្រោមជំនួយរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិសហរដ្ឋអាមេរិក ដែលហៅកាត់ថា USAID និងក្រុមហ៊ុនស៊ីអាក្រូខេមប្រូដាក់ ដែលមានបទពិសោធន៍ ក្នុងការចែកចាយផលិតផលចំណីអាហារទាំងនៅក្នុងស្រុក និងការនាំចេញ ។

ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្តបាត់ដំបង បានជួយជំរុញ និងលើកទឹកចិត្តដល់ម្ចាស់សិប្បកម្មទាំងអស់ត្រូវសិក្សាស្រាវជ្រាវកែច្នៃកសិផលបន្ថែមទៀត ប្រកបដោយគុណភាព ទាំងសុវត្ថិភាព និងអនាម័យល្អ ក៏ដូចជាការវេចខ្ចប់ ការរក្សាទុកដាក់ដើម្បីផលិតផលរបស់ខ្មែរ ទទួលបានជោគជ័យមានការគាំទ្រច្រើន។

នាឱកាសសម្ពោធ ដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផ្លូវជាតិលេខ១១ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក៏បានជំរុញឱ្យកសិករដាំ និងបង្កើនការថែទាំដំណាំមៀនប៉ៃលិនឡើងវិញ ដើម្បីត្រៀមប្រមូលផលនាំចេញទៅប្រទេសចិនដោយផ្ទាល់។ ភាគីចិនមិនត្រឹមតែសន្យាជួយដោះស្រាយបញ្ហាផ្លែមៀនប៉ៃលិនរបស់កម្ពុជា ប៉ុណ្ណោះទេ

ថៃមទាំងបានយល់ព្រមនាំចូលត្រីប្រាពីកម្ពុជា ទៅប្រទេសចិនថែមទៀតផង។

ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា បានបញ្ជាក់ថា ចិនបានសម្រេចក្នុងការសិក្សា និងវាយតម្លៃផ្នែកហានិភ័យ ផ្នែកភូតគាមអនាម័យលើផ្លែមៀន និងត្រីប្រារបស់កម្ពុជាតាមរយៈប្រព័ន្ធវីដេអូពីចម្ងាយ។ បន្ទាប់ពីការសិក្សាវាយតម្លៃដំណើរការល្អ ផ្លែមៀនរបស់កម្ពុជា នឹងអាចនាំចេញទៅចិននៅរដូវប្រមូលផលឆ្នាំក្រោយ និងត្រីប្រាអាចនាំចេញក្នុងពេលដ៏ខ្លីខាងមុខ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ cnc ចេញផ្សាយថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១។*

*ប្រភព ៖ ខេមបូឌាមីស ចេញផ្សាយថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១។*

## ១១ខែឆ្នាំ កម្ពុជា នាំចេញផលិតផលដំឡូងមីជាង២លានតោនទៅកាន់អាស៊ី អាមេរិក និងអឺរ៉ុប



*ដោយ កម្ពុជាថ្មី*

រយៈពេល១១ខែឆ្នាំ២០២១នេះ កម្ពុជាបាននាំដំឡូងមីចំនួន ២ ៣៦៤ ៥៤៨,៤២តោន ទៅកាន់បណ្តាប្រទេសមួយចំនួននៅអាស៊ី សហរដ្ឋអាមេរិក និងអឺរ៉ុប។ ក្នុងនោះមានចំណិតដំឡូងមីក្រៀមចំនួន ១ ៤៣៨ ១៧១,៦៨តោន (កើនឡើងចំនួន ៩,៥៤%)នាំទៅប្រទេសថៃ វៀតណាម និងចិន។ ដំឡូងមីស្រស់មានចំនួន ៨៨៧ ៧២០តោន (កើនឡើងចំនួន ៣៣,៦៨%) នាំទៅប្រទេសវៀតណាម និងថៃ។ ម្សៅដំឡូងមីមានចំនួន ៣០ ៤៧១,៧៤តោន (កើនឡើងចំនួន ១១%) នាំទៅប្រទេសចិន ថៃ អ៊ីតាលី បែលហ្ស៊ិក សហរដ្ឋអាមេរិក និងណេដឺឡែន រីឯកាកសំណល់ដំឡូងមីមានចំនួន៨១៨៥តោន(-៣៤,១៥%)នាំទៅប្រទេសចិន។

យោងតាមទិន្នន័យគ្រឹះភូតគាមអនាម័យជាតិនៃអគ្គនាយកដ្ឋានកសិកម្ម បានឱ្យដឹងថា ក្នុងរយៈពេល១១ខែ ឆ្នាំ២០២១នេះ ការនាំចេញកសិផលទៅក្រៅប្រទេស មានបរិមាណសរុបចំនួន ៧ ១៣១ ៩១៥,០៤ តោន ទៅកាន់ទិសដៅ ៦៨ ប្រទេស គឺមានការកើនឡើង៨៧,៥៣% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។ តាមការប៉ាន់ស្មានតម្លៃនៃការនាំចេញនេះ (មិនរាប់ផលិតផលជលផល ផលិតផលសត្វ និងព្រៃឈើ និងឈើកៅស៊ូ) មានចំនួន ៤៤៣៥ ៧៦៨ ៩០៥ ដុល្លារអាមេរិក ដែលក្នុងនោះ ការនាំចេញអង្ករមានចំនួន ៤៥៤ ៤៨០ ៨៦៦ដុល្លារអាមេរិក ការនាំចេញស្រូវមានចំនួន ៥៤៦ ៥៦៧ ៣៥០ដុល្លារអាមេរិក ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមានចំនួន ២៩៩០ ៩២៧ ១៣៥ ដុល្លារអាមេរិក ការនាំចេញកៅស៊ូធម្មជាតិមានចំនួន ៤៤៣ ៧៩៣ ៥៥៤ដុល្លារអាមេរិក (ក្នុងរយៈពេល១០ខែឆ្នាំ២០២១)៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ កម្ពុជាថ្មី ចេញផ្សាយថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២១។*

## គម្រោងកំពង់ផែទឹកជ្រៅតម្លៃ ២០០លានដុល្លារនៅខេត្តព្រះសីហនុនឹងជួយដោះស្រាយបញ្ហាដឹកជញ្ជូន




*ដោយ ខេមបូឌាមីស(ការនាំចេញទំនិញកម្ពុជានៅកំពង់ផែក្រុងព្រះសីហនុ)*

គម្រោងកំពង់ផែទឹកជ្រៅដំណាក់កាលទី១នៅខេត្តព្រះសីហនុ កំពុងរៀបចំនីតិវិធី និងការដេញថ្លៃជាអន្តរជាតិ។

គម្រោងសាងសង់កំពង់ផែទឹកជ្រៅនេះ មានតម្លៃប្រមាណជាង ២០០លានដុល្លារ ដែលជាកម្ចីសប្បទានរបស់រដ្ឋាភិបាលជប៉ុន។ កំពង់ផែនេះគ្រោងសាងសង់នាដើមឆ្នាំ២០២២ និងបញ្ចប់នៅឆ្នាំ២០២៥មានប្រវែង ៣៥០ម៉ែត្រ និងជម្រៅ ១៤,៥ម៉ែត្រ។

ប្រធានសមាគមកស្តុភារកម្មកម្ពុជា បានរៀបរាប់ថា បញ្ហាខ្វះទូរកុងតឺន័ និងថ្លៃដឹកជញ្ជូនខ្ពស់ គឺជាបញ្ហាប្រឈមខ្លាំង ក្នុងវិស័យដឹកជញ្ជូន និងឡូជីស្ទីក នៅកម្ពុជា ពិសេសអំឡុងវិបត្តិកូវីដ១៩ បានធ្វើឱ្យថ្លៃដឹកជញ្ជូនទំនិញកើនឡើងរហូត១០ដង ឯណោះ។ ហើយវិស័យនេះនាបច្ចុប្បន្ន ហាក់នៅមានកម្រិតឡើយ ដូចជាកប៉ាល់ធំៗមិនទាន់អាចចូលចតបានដែលធ្វើឱ្យថ្លៃដឹកជញ្ជូនខ្ពស់។ ក្រោយបញ្ចប់គម្រោងសាងសង់កំពង់ផែទឹកជ្រៅនេះ វិស័យដឹកជញ្ជូន និងឡូជីស្ទីក នៅកម្ពុជានឹងប្រសើរឡើង ពិសេសនឹងចូលរួមកាត់បន្ថយថ្លៃដឹកជញ្ជូនតាមផ្លូវទឹក និងជំរុញការនាំចេញ។ វិបត្តិកូវីដ១៩ បានធ្វើឱ្យប៉ះពាល់ខ្លាំងដល់វិស័យដឹកជញ្ជូននៅកម្ពុជា ធ្វើឱ្យវិនិយោគិនក្នុងវិស័យនេះមួយចំនួន ត្រូវផ្អាកសកម្មភាពអាជីវកម្មបណ្តោះអាសន្ន។ ទើបតែក្រោយពីមានការការបើកប្រទេសឡើងវិញលើគ្រប់វិស័យ វិស័យដឹកជញ្ជូន និងឡូជីស្ទីក ក៏ចាប់ផ្តើមងើបឡើងវិញជាបណ្តើរៗ។

កំពង់ផែស្វយ័តក្រុងព្រះសីហនុ សព្វថ្ងៃ អាចស្រូបយកនូវចំណែកទីផ្សារបានជាង ៧០% នៃចរាចរណ៍ទំនិញចេញ-ចូលសរុប។ ក្នុងនោះ មានកំពង់ផែជាចំណតនាវាដឹកអ្នកទេសចរណ៍, សម្រាប់ដឹកជញ្ជូនទំនិញរាយ, សម្រាប់ដឹកជញ្ជូនកុងតឺន័រឆ្លងកាត់ និងសម្រាប់ជួយគាំទ្រជាមូលដ្ឋានភស្តុភារផ្គត់ផ្គង់ការរុករកប្រេង និងការធ្វើអាជីវកម្មប្រេងក្នុងដែនសមុទ្រកម្ពុជា ដែលនឹងជំរុញដល់ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចជាតិ ផងដែរ។

បើតាមផែនការរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ បន្ទាប់ពីការសាងសង់កំពង់ផែទឹកជ្រៅជំហានទី១ រួចរាល់នៅឆ្នាំ២០២៥ នឹងបន្តសាងសង់ជំហានទី២ទៀត ដែលគ្រោងនៅឆ្នាំ២០២៨ និងជំហានទី៣ គ្រោងបញ្ចប់នៅឆ្នាំ២០៣០ ដើម្បីឱ្យនាវាទៅមកពីអាមេរិក និងអឺរ៉ុប៨៥% ចូលចតបាន មិនចាំបាច់ឆ្លងកាត់កំពង់ផែប្រទេសសិង្ហបុរី ហើយគម្រោងជំហានទី៣ អាចមានសមត្ថភាពចូលទៅអឺរ៉ុប និងអាមេរិកស្ទើរ ១០០%តែម្តង៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១។*

តារាងប្រចាំសប្តាហ៍

**រូបភាពទី១៖ ការប្រៀបធៀបការអនុវត្តចំណូលថវិកាថ្នាក់ជាតិ ក្នុងខែកញ្ញា ឆ្នាំ២០២១**




រូបភាពទី១ ខាងលើនេះ បង្ហាញពីការប្រៀបធៀបការប្រមូលចំណូល ក្នុងខែកញ្ញា ឆ្នាំ២០២១ ដែលរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន។ ចំណូលក្នុងប្រទេសសរុបមានចំនួន ១ ៤២០ ប៊ីលានរៀល ឬកើន ៤% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០ ដែលមានចំនួនប្រមាណ ១ ៣៦៤ ប៊ីលានរៀល។ ក្នុងនោះ ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេសបានកើនឡើងប្រហែល១២% បើធៀបនឹងខែកញ្ញា ឆ្នាំ២០២០។

គិតត្រឹមរយៈពេល ៩ខែ នៃឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិ ប្រមូលចំណូលក្នុងប្រទេសសរុប បានសម្រេចតាមផែនការគ្រោងដែលមានចំនួនប្រហែល ១៤ ៨៥៤ ប៊ីលានរៀល ឬស្មើនឹង៧៥% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ខណៈ ដែលការអនុវត្តក្នុងរយៈពេលដូចគ្នា ឆ្នាំ២០២០ សម្រេចបានត្រឹមតែ ៦៤% នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២០។ បើទោះបីជាវិបត្តិជំងឺកូវីដ-១៩ នៅតែបន្តជះឥទ្ធិពលលើសង្គម-សេដ្ឋកិច្ចកម្ពុជាក៏ដោយ ក៏ការប្រមូលនូវតែសម្រេចតាមផែនការ ដោយសាររាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការអន្តរាគមន៍ចាំបាច់បន្តបន្ទាប់ និងវិធានការបើកប្រទេសឡើងវិញនូវចុង ឆ្នាំ២០២១នេះ។

***ដោយ ឈន ហាំ***

*ប្រភព៖ [ការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២០ និងការអនុវត្តថវិការដ្ឋ ខែកញ្ញា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១]*

## រូបភាពទី២៖ ការប្រៀបធៀបការអនុវត្តចំណាយថវិកាថ្នាក់ជាតិ ខែកញ្ញា ឆ្នាំ២០២១




រូបភាពទី២ ខាងលើនេះ បង្ហាញពីការប្រៀបធៀបការអនុវត្តចំណាយថវិកា ក្នុងខែកញ្ញា ឆ្នាំ២០២១ ដែលរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន។ ចំណាយសរុបថ្នាក់ជាតិមានចំនួនប្រមាណ ២ ០៩០ ប៊ីលានរៀល ឬកើនឡើង ១២% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២០ ដែលមានចំនួនប្រហែល ១ ៨៦៨ ប៊ីលានរៀល។ កំណើននេះដោយសារការរឹតបន្តឹងចំណាយមិនចាំបាច់ និងការបង្វែរមុខសញ្ញាអនុវត្តឱ្យចំគោលដៅ ប្រកបដោយបុរេសកម្មសំដៅបន្តដោះស្រាយផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។ ជាក់ស្តែង ក្នុងរយៈពេល ៩ខែ នៃឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាបានចំណាយលើអត្ថប្រយោជន៍សង្គម រហូតដល់ ២ ៦០៤ ប៊ីលានរៀល ឬស្មើនឹង ១១២% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ដែលក្នុងនោះ ចំណាយលើជំនួយសង្គម ដល់ប្រជាពលរដ្ឋលើអាហារនិងសម្ភារៈ និងជំនួយសង្គម ផ្សេងៗ អនុវត្តបាន ៣៧០% និង ៣២៣% រៀងគ្នា នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០២១។

គិតត្រឹមរយៈពេល ៩ខែ នៃឆ្នាំ២០២១ ការអនុវត្តចំណាយសម្រេចបានទាបជាង ផែនការគ្រោងបន្តិច ដែលមានចំនួន ១៧ ៩១៤ ប៊ីលានរៀល ឬស្មើនឹង៦១% នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២១។***ដោយ ឈន ហាំ***

*ប្រភព៖ [ការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២០ និងការអនុវត្តថវិការដ្ឋ ខែកញ្ញា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១]*

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មផ្សេងទៀត

## ក្រុមប្រឹក្សាយោបល់រដ្ឋាភិបាលចិន ស្នើកំណត់គោលដៅកំណើនផ.ស.ស លើសពី ៥% សម្រាប់ឆ្នាំ២០២២



*ប្រភព៖ Reuters ២០២១, រូបភាព៖ Aly Song/File Photo*

ក្រុមប្រឹក្សាយោបល់ជាន់ខ្ពស់របស់រដ្ឋាភិបាលចិន បានផ្តល់អនុសាសន៍ឱ្យរដ្ឋាភិបាលកំណត់គោលដៅកំណើនសេដ្ឋកិច្ចលើសពី ៥,០% សម្រាប់ឆ្នាំ២០២២ ពោលគឺទាបជាងគោលដៅដែលបានកំណត់សម្រាប់ឆ្នាំ២០២១ ក្នុងអត្រាលើសពី ៦,០% ដោយសារការថមថយនៃសេដ្ឋកិច្ចដែលបណ្តាលមកពីការបន្តរាតត្បាតនៃជំងឺកូវីដ-១៩ និងតម្លៃទំនិញខ្ពស់។

សំណើកំណត់គោលដៅកំណើនផ.ស.ស លើសពី ៥% គឺជាការទុកឱកាសនៃការប្រែប្រួលជាក់លាក់ណាមួយ និងជាការអំពាវនាវដំប្រុងប្រយ័ត្ន។ ការកំណត់នេះ ក៏នឹងអនុញ្ញាតឱ្យភាគីទាំងអស់ផ្តោតលើការលើកកម្ពស់កំណែទម្រង់ និងការច្នៃប្រឌិត ព្រមទាំងការជំរុញឱ្យមានការអភិវឌ្ឍប្រកបដោយគុណភាពខ្ពស់ នេះបើយោងតាមសម្តីរបស់លោក Li Xuesong អ្នកស្រាវជ្រាវមកពីបណ្ឌិត្យសភាវិទ្យាសាស្ត្រសង្គមចិន (CASS)។

ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាយោបល់ក៏បានផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលកំណត់គោលដៅប្រហែល ៥,៥% សម្រាប់អត្រានិកម្មភាពនៅក្នុងទីក្រុង និងគោលដៅប្រហែល ៣,០% សម្រាប់អត្រាអតិផរណានៅឆ្នាំ ២០២២។

សេដ្ឋកិច្ចចិន ត្រូវបានរំពឹងថានឹងមានកំណើនប្រហែល ៨,០% នៅឆ្នាំ២០២១ និងទំនងជាមានកំណើនប្រហែល ៥,៣% ក្នុងឆ្នាំ២០២២ នេះបើយោងតាមសៀវភៅខៀវប្រចាំឆ្នាំស្តីពី «សេដ្ឋកិច្ច» ដែលចេញផ្សាយដោយ CASS។ ទោះយ៉ាងណា របាយការណ៍នេះក៏បានព្រមានថាការព្យាករណ៍អាចត្រូវបានកែតម្រូវទាបជាងនេះ អាស្រ័យលើស្ថានភាពនៃជំងឺកូវីដ-១៩ ខណៈ ការធ្លាក់ចុះនៃវិស័យអចលនទ្រព្យទំនងជានឹងនៅតែបន្ត និងដាក់សម្ពាធលើការចំណាយរបស់រដ្ឋាភិបាលក្នុងតំបន់នៅឆ្នាំ ២០២២។

ផ្អែកលើអនុសាសន៍គោលនយោបាយ CASS បានស្នើថាគោលនយោបាយរូបិយវត្ថុ គួរតែត្រូវបានបន្ធូរបន្ថយបន្តិចនៅឆ្នាំ២០២២ ដើម្បីទប់ទល់នឹងសម្ពាធធ្លាក់ចុះ។ បន្ថែមពីនេះ ធនាគារកណ្តាលចិនគួរតែណែនាំនូវអត្រាការប្រាក់ទាប ដើម្បីជួយដល់ក្រុមហ៊ុនតូចៗដែលកំពុងប្រឈមនឹងការចំណាយខ្ពស់ មុនពេលដែលធនាគារកណ្តាលអាមេរិកធ្វើការផ្លាស់ប្តូរគោលនយោបាយអត្រាការប្រាក់កាន់តែទាប៕ *ដោយ ស៊ិន សុភាព័*

*ប្រភព៖ Reuters ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១*

## សេដ្ឋកិច្ចវៀតណាម ត្រូវបានប៉ាន់ប្រមាណថានឹងខាតបង់ ៣៧ប៊ីលានដុល្លារអាមេរិក ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ គិតត្រឹមចុងឆ្នាំ២០២១



*ប្រភព៖ Business Standard ២០២១*

សេដ្ឋកិច្ចវៀតណាម ត្រូវបានប៉ាន់ប្រមាណថានឹងខាតបង់ប្រហែល ៣៧ប៊ីលានដុល្លារអាមេរិក ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ គិតត្រឹមចុងឆ្នាំ២០២១ នេះបើយោងតាមសម្តីរបស់លោក Nguyen Thanh Phong អនុប្រធានគណៈកម្មាធិការសេដ្ឋកិច្ចនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តវៀតណាម។

លោក Phong បានបញ្ជាក់ថា ប្រសិនបើគ្មានការរាតត្បាតនៃជំងឺកូវីដ-១៩ ទេ សេដ្ឋកិច្ចវៀតណាមអាចនឹងកើនឡើងក្នុងអត្រា ៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេល ២ឆ្នាំ ចុងក្រោយនេះ។

ប៉ុន្តែ ជាក់ស្តែង សេដ្ឋកិច្ចវៀតណាមបានកើនឡើងក្នុងអត្រា ២,៩១% នៅឆ្នាំ២០២០ និងត្រូវបានរំពឹងថានឹងកើនឡើងក្នុងអត្រាត្រឹមតែ ២,៥% ប៉ុណ្ណោះ នៅឆ្នាំ២០២១ នេះ។

លោកបានបន្ថែមថា ដើម្បីទប់ទល់នឹងផលប៉ះពាល់នៃជំងឺរាតត្បាតនេះ ចាំបាច់ត្រូវមានដំណោះស្រាយស្តារឡើងវិញយ៉ាងទូលំទូលាយជាមួយនឹងកត្តាជំរុញកំណើនចំនួន ០៤ ដែលរួមមាន៖ ការវិនិយោគ ការនាំចេញ ការប្រើប្រាស់ក្នុងស្រុក និងការផ្លាស់ប្តូរឌីជីថល។

យោងតាមការិយាល័យស្ថិតិទូទៅនៃប្រទេសវៀតណាមបានឱ្យដឹងថា កំណើនសេដ្ឋកិច្ចវៀតណាមបានកើនឡើងក្នុងអត្រាទាបត្រឹម ១,៤២% ប៉ុណ្ណោះ ក្នុងរយៈពេល ០៩ខែដំបូងនៃឆ្នាំ២០២១ នេះ ដោយសាររងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីជំងឺកូវីដ-១៩។

ទោះយ៉ាងណា ប្រទេសវៀតណាមបានប្តេជ្ញានឹងខិតខំដើម្បីសម្រេចឱ្យបាននូវអត្រាកំណើនសេដ្ឋកិច្ចក្នុងរង្វង់ពី ៦ ទៅ ៦,៥% នៅក្នុងឆ្នាំ២០២២ ក្រោមផែនការដែលទើបបានអនុម័តនាពេលថ្មីៗនេះ ដោយសភាកំពូលរបស់ខ្លួន៕ *ដោយ ស៊ិន សុភាព៉*

*ប្រភព៖ Business Standard ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១*

## ពាណិជ្ជកម្មថៃនាខែសីហាឆ្នាំ២០២១(គិតពាន់លាន$)

ការនាំចេញទំនិញសរុបរបស់ប្រទេសប្រទេសថៃមានចំនួន ២១,៩៨ ពាន់លានដុល្លារ នៅក្នុងខែសីហា ឆ្នាំ២០២១ ធៀបទៅនឹងខែរយៈពេលដូចគ្នាកាលពីឆ្នាំមុនបានកើនឡើង៨,៩៣%។ កំណើននៃការនាំចេញនោះរួមមានកំណើនផលិតផលកសិកម្ម និងផលិតផលកសិឧស្សាហកម្មបានរួមចំណែក ២៣,៦ ពាន់លានដុល្លារធៀបទៅនឹងខែរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ រីឯកំណើននៃការនាំចេញផលិតផលឧស្សាហកម្មបានរួមចំណែក ៣,៣% ធៀបទៅនឹងខែរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

គោលដីទីផ្សារ៖

- ការនាំចេញទំនិញទាំងនោះទៅកាន់ទីផ្សារចំបងបានកើនឡើង១៨,២% ក្នុងនោះទៅអាមេរិក ចិន ជប៉ុន សហភាពអឺរ៉ុប (២៧) និងអាស៊ាន (៥) រួមចំណែក ១៦,២%, ៣២,៣%, ១០,០%, ១៦,១% និង ២៦,៩% រៀងគ្នា។
- ការនាំចេញទៅកាន់ទីផ្សារបន្ទាប់បន្សំបានកើនឡើង ១៨,៤% ដែលការនាំចេញទៅកាន់អាស៊ីខាងត្បូង មជ្ឈិមបូព៌ា អាហ្វ្រិក អាមេរិកឡាទីន និងរុស្ស៊ី រួមចំណែក ៥៤,៥%, ៣១,៩%, ២៧,៥% និង ៥០,៨% រៀងគ្នា។
- ការនាំចេញទៅកាន់ទីផ្សារផ្សេងទៀតបានធ្លាក់ចុះ ៩០,១% ដោយសារការនាំចេញទៅកាន់ប្រទេសស្វីស មានការថយចុះ៩៤%។

គួបញ្ជាក់ផងដែរ ប្រទេសថៃមានឱនភាពពាណិជ្ជកម្ម ១,២២ ពាន់លានដុល្លារអាមេរិក នៅក្នុងខែសីហា ឆ្នាំ២០២១៕ *ដោយ ធីម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ២១,៩៨ |
| ការនាំចេញ | ២៣,១៩ |
| តុល្យភាពពាណិជ្ជកម្ម | -១,២២ |

*ប្រភព៖ http://www.tpso.moc.go.th*

## ពាណិជ្ជកម្មវៀតណាមពាក់កណ្តាលខែកញ្ញាឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)

យោងតាមស្ថិតិគយវៀតណាមបានបង្ហាញថា ការនាំចេញសរុបរបស់វៀតណាម មានចំនួន ១១,៥៧ ពាន់លានដុល្លារ ខណៈការនាំចូលមានចំនួន១៣,០៨ ពាន់លានដុល្លារ។ ដូច្នេះវៀតណាម មានឱនភាពពាណិជ្ជ

កម្មចំនួន ១,៥១ ពាន់លានដុល្លារ សម្រាប់រយៈពេលពាក់កណ្តាលខែដំបូង នៃខែកញ្ញា ឆ្នាំ២០២១។

បើធៀបទៅនឹងពាក់កណ្តាលខែចុងក្រោយនៃខែសីហា ឆ្នាំ២០២១ ការនាំចេញបានថយចុះដល់ ២១,១%។ ការថយចុះនោះភាគច្រើន គឺបណ្តាលមកពីការធ្លាក់ចុះលើផលិតផលទូរស័ព្ទ ទូរស័ព្ទដៃ និងគ្រឿងបន្លាស់ដែលថយចុះ ២៦% ស្មើនឹង ៨៣៨ លានដុល្លារ កុំព្យូទ័រ ផលិតផលអគ្គិសនី និងគ្រឿងបន្លាស់ថយចុះ ២៤,៦% ស្មើនឹង ៦៤៥ លានដុល្លារ ដែក និងដែកថែប ថយចុះ៤៩,១% ស្មើនឹង ៤៧៣ លានដុល្លា។

ដោយឡែក ការនាំចូលបានថយចុះ ១០,៥% ធៀបទៅនឹងពាក់កណ្តាលខែចុងក្រោយនៃខែសីហា ឆ្នាំ ២០២១ ដែលឆ្លុះបញ្ចាំងពីការធ្លាក់ចុះនៃការនាំចូលកុំព្យូទ័រ និងផលិតផលអគ្គិសនី គ្រឿងបន្លាស់ និងគ្រឿងបង្គុំចំនួន ១៥,៦% ស្មើនឹង ៦០១ លានដុល្លារ ម៉ាស៊ីន គ្រឿងបរិក្ខា និងឧបករណ៍ចំនួន ១១,១% ស្មើនឹង ២៣១ លានដុល្លារ និងត្បូងថ្មចំនួន ៥១,៥% ស្មើនឹង ១៤៧ លានដុល្លារ។៕ *ដោយ ធីម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ១១,៥៧ |
| ការនាំចេញ | ១៣,០៨ |
| តុល្យភាពពាណិជ្ជកម្ម | - ១,៥១ |

*ប្រភព៖ Vietnam Customs*

## ចិនសន្យាបើកការហោះហើរផ្ទាល់ទាំងអស់ជាមួយកម្ពុជា




នៅក្នុងជំនួបទ្វេភាគីកម្ពុជា-ចិន នៅទីក្រុងហាងចូវ ខេត្តជឺជាំង សាធារណរដ្ឋប្រជាមានិតចិន ពីថ្ងៃទី៣-៥ ខែធ្នូ ឆ្នាំ២០២១ ភាគីចិនបានអះអាងថា នឹងជួយលើកទឹកចិត្តទេសចរ និងវិនិយោគិនចិនឱ្យមកកម្ពុជា និងពិចារណាបើកជើងហោះហើរផ្ទាល់ទាំងអស់ រវាងប្រទេសទាំងពីរ។

នៅដើមឆ្នាំ២០២២ខាងមុខ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា- ចិន និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ នឹងចូលជាធរមាន ភាគីទាំងពីរ បានប្តេជ្ញាចិត្តនឹងជំរុញពាណិជ្ជកម្មទ្វេរភាគីឱ្យដល់១០ពាន់លានដុល្លារអាមេរិក នៅឆ្នាំ ២០២៣។

ភាគីកម្ពុជា បានសម្តែងការអរគុណ ចំពោះការប្តេជ្ញាចិត្តរបស់ចិន ក្នុងការបង្កើនការនាំចូល កសិផលកម្ពុជាចូលទៅកាន់ទីផ្សារចិនឱ្យបានកាន់តែច្រើនថែមទៀត។ ហើយភាគីចិន ក៏បានបញ្ជាក់ជាថ្មីនូវការគាំទ្ររបស់ខ្លួនចំពោះគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងដទៃទៀត ក៏ដូចជាកិច្ចខំប្រឹងប្រែងជួយស្តារសេដ្ឋកិច្ចរបស់កម្ពុជាក្រោយវិបត្តិជំងឺ កូវីដ-១៩។

រយៈពេល១០ខែ ឆ្នាំ២០២១នេះ ទំហំពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា-ចិន សម្រេចបានជាង ៨ ៩៣១ លានដុល្លារអាមេរិក កើនឡើង៣៨,៥៦% បើធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២០។ តាមការកត់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) គិតត្រឹមខែតុលា ឆ្នាំ២០២១ វិនិយោគចិនបានបណ្តាក់ទុននៅកម្ពុជាសរុបជាទឹកប្រាក់ប្រមាណជាង២៧ប៊ីលានដុល្លារអាមេរិក៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២១។*

## ប្រទេសកូរ៉េ នឹងធ្វើការសាងសង់ មជ្ឈមណ្ឌលពិសោធន៍ចំណីអាហារ នៅកម្ពុជា



ដោយ postkhmer

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សហការជាមួយប្រទេសកូរ៉េ សិក្សាទីតាំងសម្រាប់បង្កើតមជ្ឈមណ្ឌលពិសោធន៍ចំណីអាហារ នៅកម្ពុជា ដើម្បីបង្កភាពងាយស្រួល ដល់ក្រុមហ៊ុនឧស្សាហកម្មផលិតចំណីអាហារយកមកត្រួតពិនិត្យ សុវត្ថិភាព គុណភាព និងស្តង់ដាសម្រាប់ផ្គត់ផ្គង់នៅក្នុងទីផ្សារ និងធ្វើការនាំចេញបានលឿន។ បច្ចុប្បន្ននេះក្រុមការងារទាំងពីរ បាននិងកំពុងសិក្សាលើការបង្កើតមជ្ឈមណ្ឌលពិសោធន៍ចំណីអាហារនេះ ដើម្បីស្នើសុំជំនួយថវិកាពីរដ្ឋាភិបាលកូរ៉េលើការរៀបចំគាំទ្រលើហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកទេស ដោយដំបូង ធ្វើការសិក្សាសមិទ្ធិលទ្ធភាពដើម្បីធ្វើបានរបាយការណ៍មួយ ហើយភាគីកូរ៉េនឹងដាក់បញ្ជូនរបាយការណ៍នោះទៅរដ្ឋាភិបាលកូរ៉េ ដើម្បីទម្លាក់ថវិកា យកមកអភិវឌ្ឍមជ្ឈមណ្ឌលនេះ។

ម្ចាស់ក្រុមហ៊ុនផលិតនំស្រួយ លីលី គាំទ្រពេញទំហឹងចំពោះគម្រោង បង្កើតមជ្ឈមណ្ឌលពិសោធន៍ចំណីអាហារ នៅកម្ពុជា ដែលអាចអនុញ្ញាតឱ្យក្រុមហ៊ុននាំយកផលិតផលរបស់ខ្លួនទៅត្រួតពិនិត្យសុវត្ថិភាព និងគុណភាពបាន ដោយមិនតម្រូវឱ្យនាំចេញទៅពិនិត្យនៅក្រៅប្រទេស។

នៅក្នុងប្រទេសកម្ពុជាក៏មានមជ្ឈមណ្ឌលពិសោធន៍ចំណីអាហារនេះដែរ ប៉ុន្តែមិនទាន់គ្រប់លក្ខខណ្ឌសម្រាប់ប្រទេសមួយចំនួនដែលត្រូវការនោះទេ។ ដូច្នេះនៅពេលដែលប្រទេសកូរ៉េ មកវិនិយោគបង្កើតមជ្ឈមណ្ឌលពិសោធន៍នេះ នឹងចូលរួមពិសោធន៍បានច្រើនទៅតាមតម្រូវការ និងចំណេញទាំងពេលវេលា និងថវិកា។ មិនត្រឹមតែប៉ុណ្ណោះ នឹងចូលរួមជំរុញដល់ការនាំចេញបានកាន់តែលឿន និងមានចំនួនច្រើនផងដែរ៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព ៖ postkhmer ចេញផ្សាយថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១។*

## សេដ្ឋកិច្ចសកល

### IMF ទំនងជានឹងកាត់បន្ថយការព្យាករណ៍កំណើនតំបន់អឺរ៉ូចំពេលអតិផរណា ដោយសារការភ័យខ្លាច អូមីក្រុង



*ប្រភព៖ Pool | Getty Images News | Getty Images*

មូលនិធិរូបិយវត្ថុអន្តរជាតិ អាចនឹងកាត់បន្ថយការព្យាករណ៍កំណើនសម្រាប់តំបន់ចាយប្រាក់អឺរ៉ូ ខណៈដែលមានការព្រួយបារម្ភអំពីការប្រែប្រួល នៃវីរុសបម្លែងថ្មី អូមីក្រុង និងអតិផរណាដែលកើនឡើងជាបន្តបន្ទាប់។

មូលនិធិបាននិយាយកាលពីខែតុលាថា ខ្លួនរំពឹងថាសេដ្ឋកិច្ចតំបន់ចាយប្រាក់អឺរ៉ូនឹងកើនឡើង ៤.៣% ក្នុងឆ្នាំ ២០២២។ ឥឡូវនេះ ស្ថាប័ននេះបានព្រមានអំពី "លទ្ធភាពនៃការកែប្រែតិចតួច" នៅពេលដែលវាបង្ហាញពីការប៉ាន់ស្មានថ្មីនៅខែក្រោយ។

ការកើនឡើងសម្ពាធនៃការផ្គត់ផ្គង់ តម្លៃថាមពលខ្ពស់ និងការដាក់ឱ្យប្រើប្រាស់ឡើងវិញនូវការរឹតបន្តឹងសង្គមថ្មីនៅក្នុងបណ្តាប្រទេសក្នុងតំបន់ចាយប្រាក់អឺរ៉ូមួយ

ចំនួន គឺជាកង្វល់កំពូលសម្រាប់មូលនិធិ។ វាកើតឡើងនៅពេលដែលនៃវិរុសបម្លែងថ្មី អូមីក្រុង ដែលត្រូវបានកំណត់អត្តសញ្ញាណថ្មីត្រូវបានរាយការណ៍នៅក្នុងប្រទេសចំនួនកើនឡើងនៅជុំវិញពិភពលោក។ ហើយយោងតាម IMF ជំងឺរាតត្បាតនៅតែជាហានិភ័យលេខមួយចំពោះកំណើនសេដ្ឋកិច្ច។

បន្ថែមពីលើជំងឺរាតត្បាតនេះ ក៏មានការព្រួយបារម្ភអំពីថាតើអតិផរណាខ្ពស់នៅដែលបានកើតឡើងនៅទីនេះ ខណៈដែលអតិផរណាតំបន់អឺរ៉ូ បានឡើងដល់កម្រិតខ្ពស់បំផុតមិនធ្លាប់មានក្នុងខែវិច្ឆិកា។ យោងតាមការព្យាករណ៍របស់ IMF អតិផរណាតំបន់ចាយប្រាក់អឺរ៉ូត្រូវបានព្យាករណ៍ថានឹងធ្លាក់ចុះរហូតដល់ឆ្នាំ២០២២ ហើយនឹងនៅតែស្ថិតនៅក្រោមគោលដៅ២% របស់ ECB ក្នុងរយៈពេលមធ្យម។

ទោះជាយ៉ាងណាក៏ដោយ IMF បាននិយាយថាការចរចាប្រាក់ឈ្នួលគឺជាតំបន់ដែលត្រូវពិនិត្យមើល ហើយកំណើនប្រាក់ឈ្នួលគឺជាធាតុផ្សំសំខាន់នៃផលប៉ះពាល់នៃអតិផរណាលើគ្រួសារ ដូចជាប្រសិនបើប្រាក់ឈ្នួលកើនឡើងទាបជាងអតិផរណា អ្នកប្រើប្រាស់នឹងមានអំណាចទិញតិចជាង ដែលអាចមានឥទ្ធិពលលើអត្រាដែលធនាគារកណ្តាលរឹតបន្តឹង។*ដោយ វត្ថា វង្សវឌ្ឍនៈ ប្រភព៖ គេហទំព័រសារព័ត៌មាន CNBC ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២១*

## តើសេដ្ឋកិច្ចចិនឆ្នាំ២០២២ នឹងប្រែប្រួល ឬជួបកត្តាប្រឈមអ្វីខ្លះ?



*ដោយ ខេមបូណ្ណមីស(អនុប្រធានគណៈកម្មាធិការសេដ្ឋកិច្ចនិងនយោបាយចិន)*

ទីប្រឹក្សាជាន់ខ្ពស់របស់រដ្ឋាភិបាលចិនរូបនេះបានព្រមានថា កំណើនសេដ្ឋកិច្ចចិននៅឆ្នាំ២០២២ អាចជួបបញ្ហាប្រឈមធំបំផុតមួយ។ នេះគឺដោយសារតែមានកំណើនយឺតជាងការរំពឹងទុកក្នុងឆ្នាំ២០២១។ សេដ្ឋកិច្ចចិននៅត្រីមាសទី៣ឆ្នាំនេះ បានធ្លាក់ចុះច្រើនមែនទែន បើធៀបនឹងត្រីមាសដំបូង។ ក្នុងរយៈពេលបីខែដំបូងឆ្នាំ២០២១ សេដ្ឋកិច្ចចិនមានកំណើនរហូតដល់ជាង១៨%ប៉ុន្តែបានធ្លាក់ចុះមកនៅត្រឹមតែជិត៥%ក្នុងត្រីមាសទី៣នេះ ហើយត្រីមាសចុងក្រោយ ត្រូវបានគេរំពឹងថា នឹងបន្តមានកំណើនយឺតជាងនេះទៀត។ ការរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ចចិននៅឆ្នាំ២០២២ ទាមទារឱ្យរដ្ឋអំណាចក្រុងប៉េកាំង អនុវត្តនូវវិធានការនិងគោលនយោបាយថ្មី ស្របពេលដែលសេដ្ឋកិច្ចចិនកំពុងមានកំណើនយឺតនៅចុងឆ្នាំ២០២១នេះ ដែលបណ្តាលឱ្យមានក្តីបារម្ភចំពោះភាពមិនច្បាស់លាស់លើការអភិវឌ្ឍប្រទេសជាតិនៅឆ្នាំក្រោយ។ អ្នករៀបចំគោលនយោបាយរបស់រដ្ឋាភិបាលប៉េកាំង គួរតែបង្កើតគោលនយោបាយគាំទ្រឱ្យបានច្រើនសម្រាប់ឆ្នាំ២០២២ ដើម្បីឆ្លើយតបទៅនឹងការធ្លាក់ចុះនៃសេដ្ឋកិច្ចនិងការកើនឡើងនៃបញ្ហាប្រឈមផ្នែកខាងក្រៅ។ ដើម្បី

រក្សាសន្ទុះនៃការងើបឡើងវិញនៅឆ្នាំក្រោយ ក្រុងប៉េកាំងគួរតែខិតខំប្រឹងប្រែងឱ្យបានខ្លាំង ដើម្បីរក្សាស្ថិរភាពអត្រាកំណើន ព្រោះការអភិវឌ្ឍដែលមានគុណភាព និងប្រសិទ្ធភាពខ្ពស់ ចាំបាច់ត្រូវមានកំណើនសេដ្ឋកិច្ចថេរ ឬក្នុងអត្រាសមហេតុសមផលមួយ ជៀសវាងការងើបឡើង និងធ្លាក់ចុះ គ្មានលំនឹងច្បាស់លាស់។

ធនាគារចិន Bank of China ដែលជាធនាគារធំ១ ក្នុងចំណោមធនាគារធំៗទាំង៤ដែលគ្រប់គ្រងដោយរដ្ឋាភិបាលចិន បានព្យាករសេដ្ឋកិច្ចចិននៅឆ្នាំក្រោយថា នឹងមានកំណើនប្រមាណ៥%ប៉ុណ្ណោះ តិចជាងការព្យាកររបស់ IMF ដែលប៉ាន់ស្មានថា ចិននឹងមានកំណើនសេដ្ឋកិច្ច ៥,៥%នៅឆ្នាំ២០២២។

ចិនជាប្រទេសដែលមានសេដ្ឋកិច្ចធំបំផុតទីពីរ របស់ពិភពលោក កំពុងប្រឈមមុខនឹងបញ្ហាជាច្រើន រាប់ចាប់តាំងពីកូវីដ១៩បំប្លែងខ្លួនថ្មីអូមីក្រុង ហានិភ័យហិរញ្ញវត្ថុ ដែលបណ្តាលមកពីបញ្ហាបំណុលរបស់ក្រុមហ៊ុនអចលនទ្រព្យដ៏ធំ Evergrande និងទំនាក់ទំនងពាណិជ្ជកម្មមិនល្អជាមួយសហរដ្ឋអាមេរិកជាដើម៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូឌាមីស ចេញផ្សាយថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១។*

## ក្នុងឆ្នាំ២០២០ឧស្សាហកម្មអាវុធ រកប្រាក់បាន៥៣១ ពាន់លានដុល្លារ(ក្រុមហ៊ុនអាមេរិកឈរនៅលំដាប់កំពូល)



*ប្រភព៖ Al Jazeera*

នៅឆ្នាំ២០២០ ការលក់អាវុធ និងសេវាយោធាដោយក្រុមហ៊ុនលក់អាវុធធំៗទាំង១០០នៅលើពិភពលោករកកម្រៃបានដល់ទៅ៥៣១ពាន់លានដុល្លារ កើនឡើង១,៣%បើធៀបទៅនឹងឆ្នាំ២០១៩។ ក្នុងនោះ ក្រុមហ៊ុនលក់អាវុធនៅសហរដ្ឋអាមេរិកចំនួន៤១នៅតែបន្តឈរលំដាប់កំពូលនៃឧស្សាហកម្មអាវុធ ដោយរកប្រាក់បាន២៨៥ពាន់លានដុល្លារ ឬស្មើនឹង៥៤%នៃការលក់អាវុធសរុប នៅក្នុងចំណោមក្រុមហ៊ុនធំៗទាំង១០០។ ក្រុមហ៊ុនលក់អាវុធដែលគ្រងតំណែងរាប់ពីលេខរៀងទី១ដល់ទី៥ ចាប់តាំងពីឆ្នាំ២០១៨មក សុទ្ធតែជាក្រុមហ៊ុនមានមូលដ្ឋាននៅក្នុងសហរដ្ឋអាមេរិក។

ការលក់អាវុធរបស់ក្រុមហ៊ុនធំៗរបស់ចិនរកប្រាក់បាន៦៦,៨ពាន់លានដុល្លារកាលពីឆ្នាំ២០២០ ឬកើនឡើង១,៥% បើធៀបទៅនឹងឆ្នាំ២០១៩ ខណៈការលក់អាវុធរបស់រុស្ស៊ីមានការថយចុះ។ ឆ្នាំ២០២០ គឺជាឆ្នាំទី៦ជាប់គ្នា ដែលវិស័យលក់អាវុធរបស់ក្រុមហ៊ុនធំៗទាំង១០០ អាចរក្សាបាននូវកំណើន បើទោះជាសេដ្ឋកិច្ចពិភពលោកកំពុងរងផលប៉ះពាល់ដោយសារ COVID-19 ក៏ដោយ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ams ចេញផ្សាយថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី១៣ ខែធ្នូ ឆ្នាំ២០២១

- កំណើននៃការលក់រាយនៅក្នុងប្រទេសទួរគីបានកើន1.20%នៅក្នុងខែកញ្ញា ឆ្នាំ 2021
- កំណើន អត្រាអតិផរណាលក់រាយប្រចាំឆ្នាំនៅក្នុងប្រទេសឥណ្ឌា ក្នុងខែតុលា ឆ្នាំ 2021

ថ្ងៃអង្គារ ទី១៤ ខែធ្នូ ឆ្នាំ២០២១

- កំណើនតម្លៃនៃការនាំចេញនៅក្នុងប្រទេសកូរ៉េខាងត្បូង ក្នុងខែតុលា និងខែកញ្ញា ឆ្នាំ 2021។

- អត្រានីកម្មភាព របស់ចក្រភពអង់គ្លេសបានធ្លាក់ ខែកញ្ញា ឆ្នាំ 2021

ថ្ងៃពុធ ទី១៥ ខែធ្នូ ឆ្នាំ២០២១

- អត្រាអតិផរណានៅអាហ្សង់ទីន បានថយចុះនាខែតុលា និងខែកញ្ញា ឆ្នាំ 2021
- ភាពអត់ការងារធ្វើនៅទីក្រុង របស់ប្រទេសចិនមាននៅក្នុងខែតុលា ឆ្នាំ 2021 មិនផ្លាស់ប្តូរ

ថ្ងៃព្រហស្បតិ៍ ទី១៦ ខែធ្នូ ឆ្នាំ២០២១

- ប្រទេសជប៉ុន បានចុះបញ្ជីឱនភាពពាណិជ្ជកម្មដោយមិនបានរំពឹងទុក ក្នុងខែតុលា ឆ្នាំ 2021
- កំណើនអត្រានីកម្មភាព តាមរដូវកាលរបស់ប្រទេសអូស្ត្រាលី

ថ្ងៃសុក្រ ទី១៧ ខែធ្នូ ឆ្នាំ២០២១

- កណើននៃតម្លៃប្រាក់កម្ចីនៅក្នុងប្រទេសឥណ្ឌូនៅក្នុងខែតុលា ឆ្នាំ 2021
- ឱនភាពពាណិជ្ជកម្ម របស់ប្រទេសអេស្ប៉ាញបានកើនឡើង ក្នុងខែកញ្ញា ឆ្នាំ 2021៕